សួស្តី នៅក្នុងរូបភាពនេះគឺនិយាយអំពីខារ៉ាអូខេ។
ដែលនៅក្នុងរូបភាពទី ១ យើងឃើញមានស្ត្រីម្នាក់ ដែលគាត់ចងសក់ឡើងទៅលើ
គាត់ពាក់អាវពណ៌ស្វាយដៃខ្លី ជាមួយនឹងខោពណ៌ខ្មៅជើងវែង។
ដោយសារតែថ្ងៃនេះគឺជាថ្ងៃខួបកំណើតរបស់គាត់ ដូច្នេះគាត់ក៏បានមកបបួលពួកម៉ាករបស់គាត់
ដែលមានស្រីៗចំនួនបួន ចំនួនបីនាក់ ដើម្បីទៅច្រៀងខារ៉ាអូខេជាមួយគ្នា
នៅថ្ងៃខួបកំណើតរបស់គាត់។ ពួកគាត់ទាំងបួននាក់ គឺជាមិត្តភក្តិជិតស្និទ្ធនឹងគ្នា
ប្រហែលជាពួកគាត់ស្គាល់គ្នាតាំងពីពួកគាត់រៀននៅសាលា ដូច្នេះនៅថ្ងៃខួបកំណើតរបស់គាត់
គាត់ចង់ចំណាយពេលសប្បាយជាមួយនឹងពួកម៉ាករបស់គាត់ ដោយការទៅច្រៀងខារ៉ាអូខេ
ដោយយើងឃើញពួកម៉ាករបស់គាត់ទី ១ បួងសក់ឡើងទៅលើ ពាក់អាវពណ៌ពងមាន់ដៃខ្លី
ជាមួយនឹងខោជើងវែងពណ៌ស ពួកម៉ាកគាត់ទី ២ គឺ គាត់ពាក់អាវយឺត
គាត់ពាក់អាវយឺតពណ៌ប្រផេះដៃខ្លីជាមួយនឹងសំពត់ត្រឹមជង្គង់ពណ៌ស សក់របស់គាត់គឺត្រឹម
សក់របស់គាត់ត្រឹមស្មា សក់របស់គាត់ត្រឹមស្មា និងពួកម៉ាកគាត់ម្នាក់ទៀតគឺពាក់អាវយឺតពណ៌សដៃខ្លី
ដែលជាមួយនឹងសំពត់ត្រឹមជង្គង់ ពណ៌ខៀវ សក់របស់គាត់គឺសក់ខ្លី។ អញ្ចឹងពួកគាត់ទាំងបួននាក់
ពួកគាត់ទាំងបួននាក់ ចង់ទៅច្រៀងខារ៉ាអូខេ។

បន្ទាប់មកទៀត រូបភាពទី ២ រូបភាពទី ២ ក្រោយពេលដែលពួកគាត់ជជែកគ្នា
ជជែកគ្នារកកន្លែងច្រៀងខារ៉ាអូខេ ពួកគាត់ទាំងបួននាក់ក៏បានដើរមកផ្សារទំនើប
ដោយយើងដឹងហើយថា ផ្សារទំនើបគឺជាកន្លែងដែលមានលក់ ដែលមានលក់នូវរបស់ជាច្រើន
និងមានហាងជាច្រើននៅក្នុងផ្សារទំនើប និងមាន និងមានខារ៉ាអូខេ និងមានខារ៉ាអូខេ
និងមានរោងកុនផងដែរ។ ដូច្នេះពួកគាត់ទាំងបួននាក់បានដើរមកផ្សារទំនើបនោះ
ដើម្បីឡើងទៅខាង ដើម្បីឡើងទៅជាន់ខាងលើច្រៀងខារ៉ាអូខេនៅថ្ងៃខួបកំណើតរបស់គាត់។
ខារ៉ាអូខេ មិនត្រឹមតែមាននៅក្នុងផ្សារទំនើបទេ ខារ៉ាអូខេស្ទើរតែមាននៅគ្រប់ទីកន្លែង គឺអ្នកខ្លះ
គឺគាត់បើកខារ៉ាអូខេនៅតាមផ្ទះ មានន័យថាផ្ទះរបស់គាត់ គាត់តែងលម្អជាមួយនឹងភ្លើងពណ៌
និងមានការតុបតែងយ៉ាងស្រស់ស្អាត គាត់ មានការតុបតែងយ៉ាងស្រស់ស្អាត
អញ្ចឹងគាត់អាចបើកជាបន្ទប់ ឬក៏ជាកន្លែងខារ៉ាអូខេបាន។ ដោយ និង និងផ្ទះខ្លះគាត់បើកខារ៉ាអូខេ
គឺមានតម្លៃថោក។ មានន័យថាយើងទៅច្រៀងនៅទីនោះ មានតម្លៃថោក។ ប៉ុន្តែហាង ហាង
ប៉ុន្តែហាង ហាងខ្លះក៏បើកខារ៉ាអូខេធំ ហាងខ្លះក៏បើកខារ៉ាអូខេធំ
អញ្ចឹងពេលខ្លះក៏មានតម្លៃថ្លៃផងដែរ។ អញ្ចឹងអាស្រ័យទៅលើទីតាំង និងកន្លែង។
អញ្ចឹងពួកគាត់ទាំងបួននាក់ ពួកគាត់ទាំងបួននាក់ បានដើរទៅ បានដើរទៅផ្សារទំនើប
ដើម្បីច្រៀងខារ៉ាអូខេនៅទីនោះ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៣ រូបភាពទី ៣ ដោយសារតែកន្លែងដែលច្រៀងខារ៉ាអូខេនោះ
គឺនៅជាន់ខាងលើ ដូច្នេះពួកគាត់មិនបាន ដូច្នេះពួកគាត់មិនបានដើរមើលនៅជុំវិញផ្សារទេ
ពួកគាត់ដើរសំដៅទៅជណ្ដើរយន្តដើម្បីឡើងទៅជាន់ខាងលើតែម្ដង។ ដោយយើងឃើញស្ត្រីដែល
ដែលគាត់ ស្ត្រីដែលថ្ងៃនេះគឺជាថ្ងៃខួបកំណើតរបស់គាត់ គាត់បានដើរនាំមុខ
គាត់បានដើរទៅចុចប៊ូតុង ដើម្បីឡើងទៅខាងលើ ដើម្បីឡើងទៅខាងលើតាមជណ្ដើរយន្ត។
អញ្ចឹងផ្សារទំនើបមានច្រើនជាន់ អ្នកខ្លះគាត់ចូលចិត្តឡើងតាមជណ្ដើរជើង
អ្នកខ្លះគាត់ចូលចិត្តឡើងតាមជណ្ដើរយន្ត ប៉ុន្តែគ្រាន់តែការឡើងតាមជណ្ដើរជើង ពេលខ្លះហត់បន្តិច
ពេលខ្លះហត់បន្តិច ប៉ុន្តែអ្នកខ្លះគាត់ចូលចិត្តដើរជុំវិញផ្សារ ដើម្បីមើលរបស់ដែលលក់នៅ
នៅក្នុងផ្សារនោះ អញ្ចឹងគាត់ចូលចិត្តឡើងតាមជណ្ដើរជើង
ប៉ុន្តែជាទូទៅផ្សារទំនើបភាគច្រើនគឺមានជណ្ដើរយន្ត ភាគច្រើនគឺប្រើជណ្ដើរយន្ត
ដោយសារតែផ្សារទំនើបមានច្រើនជាន់ អញ្ចឹងភាគច្រើនគឺប្រើជណ្ដើរយន្ត។
អញ្ចឹងពួកគាត់ទាំងបួននាក់បាន ពួកគាត់ទាំងបួននាក់ ដែលមានស្ត្រីដែលគាត់
ដែលមានស្ត្រីដែលគាត់មានថ្ងៃខួបកំណើតនៅថ្ងៃនេះ
ដែលគាត់បានបបួលពួកម៉ាករបស់គាត់ទាំងបីនាក់មកច្រៀងខារ៉ាអូខេ
គាត់ក៏បានដើរទៅចុចប៊ូតុងជណ្ដើរយន្តនោះ ដើម្បីឲ្យជណ្ដើរយន្តបើក
ដូច្នេះពួកគាត់អាចដើរចូលទៅខាងក្នុងដើម្បីឡើងទៅខាងលើបាន។

បន្ទាប់មកទៀតរូបភាពទី ៤ រូបភាពទី ៤ ពួកគាត់ទាំងបួននាក់ក៏បានឡើងមកដល់ជាន់ខាងលើ
ពួកគាត់ទាំងបួននាក់ក៏បានដើរចូលក្នុងបន្ទប់ខារ៉ាអូខេ។
ពីមុនការច្រៀងខារ៉ាអូខេនៅតាមផ្សារទំនើបគឺយើងប្រើកាក់ មានន័យថាយើងបង់ ២ ដុល្លារ ឬក៏ ៣
ដុល្លារ ដើម្បីទទួលបានកាក់ពីរ កាក់មួយប្រើបានកន្លះម៉ោង
កាក់មួយទៀតគឺប្រើបានកន្លះម៉ោងទៀត។ អញ្ចឹងកាលពីមុនការច្រៀងខារ៉ាអូខេគឺប្រើកាក់
យើងញាត់[...] យើងញាត់កាក់ចូលទៅខាងក្នុង អញ្ចឹងយើងអាចច្រៀងបាន
នៅពេលដែលកាក់នោះផុតម៉ោងហើយ អញ្ចឹងយើងមិនអាចច្រៀងបានទៀតទេ។
អញ្ចឹងយើងត្រូវទៅទិញកាក់បន្ថែមទៀត ដើម្បីញាត់ចូល ដើម្បីអាចច្រៀងបានទៀត។
ប៉ុន្តែឥឡូវនេះគឺយើងមិនចាំបាច់ទិញកាក់ ឬញាត់ចូលទៅខាងក្នុងទៀតទេ នៅផ្សារទំនើបឥឡូវនេះ
យើងមានបន្ទប់ដូចជាការ ដូចជាការ ដូចជាការច្រៀងនៅតាមផ្ទះដែរ ឬក៏ការច្រៀងនៅតាម
នៅតាមហាង នៅតាមហាង ឬក៏កន្លែងខារ៉ាអូខេធំៗដែរ។ អញ្ចឹងយើងអាចចូលមកខាងក្នុងបន្ទប់
យើងអាចច្រៀង អញ្ចឹងអ្នកដែលគាត់បើកខារ៉ាអូខេនោះ ឬក៏បុគ្គលិកនៅទីនោះ គាត់នឹងគិតជាម៉ោង
មានន័យថាប្រសិនបើយើងច្រៀងចំនួនមួយម៉ោង គាត់គិតមួយម៉ោង ចំនួនមួយម៉ោង ១៥ នាទី
គាត់គិតមួយម៉ោង ១៥ នាទី។ អញ្ចឹងទៅតាមម៉ោង ឬក៏នាទីដែលយើងច្រៀងចប់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

និងយើងចង់ត្រលប់ទៅវិញ។ អញ្ចឹងឥឡូវនេះ ខារ៉ាអូខេនៅតាមផ្សារទំនើប
យើងអាចច្រៀងដោយគិតម៉ោង មិនចាំបាច់ទិញកាក់ដូចជា ដូចជាពីមុនទេ ដូចជាពីមុនទេ។ ពីមុន
ការច្រៀងខារ៉ាអូខេដោយគិតម៉ោងមានតែនៅតាមផ្ទះ ឬក៏តាមកន្លែងខារ៉ាអូខេធំៗ តាមខារ៉ាអូខេធំៗ
អញ្ចឹងគេច្រៀងគិតម៉ោង ប៉ុន្តែនៅតាមផ្សារទំនើបច្រៀងដោយការញាត់កាក់។
ប៉ុន្តែឥឡូវនេះនៅតាមផ្សារទំនើបគឺច្រៀងគិតម៉ោង ដូចជាកន្លែងខារ៉ាអូខេធំៗ
ឬក៏ខារ៉ាអូខេនៅតាមផ្ទះដែរ។ អញ្ចឹងពួកគាត់ទាំងបី យើងឃើញពួកគាត់ទាំងបី
យើងឃើញពួកគាត់ទាំងបួននាក់ មានទឹកមុខយ៉ាងសប្បាយរីករាយ យ៉ាងសប្បាយរីករាយ
ដោយសារតែពួកគាត់បានចូលមកក្នុងបន្ទប់ខារ៉ាអូខេ និងឃើញបន្ទប់នោះធំ
និងឃើញបន្ទប់នោះធំ។ យើងឃើញ យើងឃើញនៅក្នុងបន្ទប់ខារ៉ាអូខេនោះគឺមានតុធំមួយ
មានតុធំមួយ និងមានសៀវភៅបទចម្រៀងមួយក្បាល ដាក់នៅលើតុនោះ និងមានកៅអី
ឬក៏សាឡុងចំនួនពីរ ចំនួនពីរដាក់នៅសងខាងតុនោះ នៅខាងមុខតុយើងឃើញ
នៅខាងមុខតុជាប់នឹងជញ្ជាំង យើងឃើញមានទូរទស្សន៍ធំមួយ
ដែលប្រើសម្រាប់នៅពេលដែលយើងច្រៀងខារ៉ាអូខេ
យើងអាចអានអក្សរដែលមាននៅក្នុងទូរទស្សន៍នោះ យើងអានអក្សរតាម តាមទូរទស្សន៍នោះ
មានន័យថាអ្នកខ្លះគាត់ចេះច្រៀង ប៉ុន្តែគាត់អត់ចាំបទចម្រៀងដែលត្រូវច្រៀង ត្រូវច្រៀងយ៉ាងម៉េច
ដូច្នេះគាត់អាចអានតាមអក្សរដែលមានរត់នៅក្នុងទូរទស្សន៍ រត់នៅតាមទូរទស្សន៍នោះ
បន្ទាប់មកនៅខាងក្រោមគឺជាកន្លែងសម្រាប់ចាក់បទចម្រៀង យើងឃើញមានក្បាលមេក្រូចំនួនពីរ
យើងឃើញមានក្បាលមេក្រូចំនួនពីរ ដែលក្បាលមេក្រូយើងប្រើសម្រាប់ច្រៀង ប្រើសម្រាប់ច្រៀង
និងមាន និងយើងឃើញមានថូផ្កាមួយ ដែលមានផ្កានៅខាងក្នុងនោះ
ដែលដាក់នៅអែបជាប់នឹងជញ្ជាំងក្បែរនឹង នៅចន្លោះសាឡុងទាំងពីរនោះ
នៅចន្លោះសាឡុងទាំងពីរនោះ អញ្ចឹងបន្ទប់ខារ៉ាអូខេគឺមានពីរ បន្ទប់ខ្លះគឺតូច បន្ទប់ខ្លះគឺធំ
អញ្ចឹងទៅតាម ទៅតាមបន្ទប់ អញ្ចឹងតម្លៃគឺទៅតាមបន្ទប់។ បន្ទប់ដែល ដែលតូចគឺតម្លៃថោក
បន្ទប់ដែលធំគឺតម្លៃរាងថ្លៃបន្តិច ប៉ុន្តែមិនថ្លៃណាស់ណាទេ គឺគ្រាន់តែថ្លៃបន្តិចបន្តួចតែប៉ុណ្ណោះ។
អញ្ចឹងអ្នកខ្លះគឺគាត់ ប្រសិនបើគាត់មកគ្នាច្រើន គាត់ចូលចិត្តចូលបន្ទប់ធំ
អ្នកខ្លះទៀតគាត់មកគ្នាគាត់តិច អញ្ចឹងគាត់ចូលចិត្តចូលបន្ទប់តូចល្មម សម្រាប់គ្នារបស់គាត់
សម្រាប់គ្នារបស់គាត់។ អញ្ចឹងពួកគាត់ទាំង
អញ្ចឹងពួកគាត់ទាំងបួននាក់បានចូលមកដល់បន្ទប់ខារ៉ាអូខេ
ដោយម្នាក់ៗមានទឹកមុខសប្បាយរីករាយ ដូច្នេះថ្ងៃនេះពួកគាត់នឹងអបអរថ្ងៃខួបកំណើត
ថ្ងៃខួបកំណើត នៅក្នុង នៅក្នុងបន្ទប់ខារ៉ាអូខេនេះ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៥ រូបភាពទី ៥ ជាទូទៅ នៅពេលដែលយើងចូលមកច្រៀងនៅ នៅបន្ទប់ខារ៉ាអូខេ អញ្ចឹងបុគ្គលិកនៅទីនោះតែងតែលើក តែងតែ តែងតែសួរយើង ថាយើងត្រូវការញ៉ាំភេសជ្ជៈអ្វី និងត្រូវការញ៉ាំម្ហូប និងត្រូវញ៉ាំអាហារសម្រន់ ឬក៏ម្ហូបអ្វី អាហារសម្រន់ ឬក៏ជានំកញ្ចប់ ឬក៏ជានំកញ្ចប់ ឬក៏ជាគ្រឿងម្ហូរ ដែលគ្រឿងម្ហូរមានដូចជាផ្លែស្វាយ របស់ណាដែលរាងជូរៗ សម្រាប់ញ៉ាំនិងច្រៀងលេង។ អញ្ចឹងយើងឃើញរូបភាពទី ៥ យើងឃើញមានទឹក អ្នកខ្លះគាត់បានហៅទឹកសុទ្ធ អ្នកខ្លះគាត់បានហៅតែក្រូចឆ្មារ អ្នកខ្លះគាត់បានហៅទឹកក្រូច ឬក៏កូកាកូឡា ដែលយើងឃើញ នៅក្នុងថាសទីមួយ យើងឃើញមានដូចជា ប្រហែលជាទឹកក្រូច យើងឃើញមានទឹកក្រូច និងកែវទឹកចំនួន និងកែវទឹកចំនួន[បួន] ចំនួន និងកែវទឹកចំនួន ៦ ដោយយើងឃើញ កែវទឹកធំៗចំនួនបួន និងកែវទឹកតូចៗចំនួនពីរ។ ដែលយើងឃើញកែវដែលមានទឹកពណ៌បៃតងជាមួយនឹងចំណិតក្រូច ដាក់នៅខាងលើ ប្រហែលជា ប្រហែលជាតែក្រូចឆ្មារ អញ្ចឹងប្រហែលជាតែក្រូចឆ្មារ ពីព្រោះពេលខ្លះ នៅពេលដែលគាត់ច្រៀង ពេលខ្លះធ្វើឲ្យគាត់ស្អកក ឬក៏ឈឺក ដូច្នេះគាត់អាចញ៉ាំតែក្រូចឆ្មារ ដើម្បីជួយសម្រួលបំពង់ករបស់គាត់ ដើម្បីអាចច្រៀង ដើម្បីអាចច្រៀងឲ្យពីរោះ និង ដើម្បីកុំឲ្យឈឺកផងដែរ។ អញ្ចឹងអ្នកខ្លះគាត់ចូលខារ៉ាអូខេគាត់ញ៉ាំស្រាបៀរ គាត់ញ៉ាំស្រាបៀរ តែអ្នកខ្លះទៀតគាត់ញ៉ាំទឹកក្រូចធម្មតា អាស្រ័យទៅលើមនុស្ស។ និងយើងឃើញថាសទី ២ គឺយើងឃើញមានម្ហូប យើងឃើញមានម្ហូបជាច្រើន និង ដែលជាម្ហូបទាំងអស់នោះ គ្រាន់តែជាម្ហូបសម្រន់ មានន័យថា ម្ហូបទាំងអស់នេះគ្រាន់តែជាម្ហូបដែលយើងញ៉ាំលេងតែប៉ុណ្ណោះ មិនមែនញ៉ាំដូចជាញ៉ាំបាយ ឬក៏ញ៉ាំម្ហូបដែលនៅតាមភោជនីយដ្ឋាននោះទេ គ្រាន់តែជាម្ហូបដែលយើងញ៉ាំលេង ញ៉ាំលេង នៅពេលដែលយើងច្រៀងខារ៉ាអូខេ។ ដែលយើងឃើញមានដូចជា ប្រហែលជានំកញ្ចប់ ឬក៏ប្រហែលជា យើងឃើញមើលទៅដូចជា ប្រហែលជាស្វាយ ឬក៏[ប្រហែលជា] ប្រហែលជាស្វាយ ឬក៏ជាអាហារសម្រន់ផ្សេងៗទៀត ដែលពួកគាត់បានហៅឲ្យ [...] ដែលពួកគាត់បានហៅដើម្បីយកមកញ៉ាំ នៅពេលដែលគាត់ ពួកគាត់ច្រៀង។ នៅពេលគាត់ ពួកគាត់ច្រៀង អញ្ចឹងពួកគាត់អាចញ៉ាំលេងបណ្តើរ អាចច្រៀងលេងបណ្តើរយ៉ាងសប្បាយរីករាយ។

បន្ទាប់មកទៀតរូបភាពទី ៦ រូបភាពទី ៦ យើងឃើញ ក្រោយពេលដែលពួកគាត់ ក្រោយពេលដែលពួកគាត់បាន ក្រោយពេលដែលពួកគាត់អង្គុយ អង្គុយនៅក្នុងបន្ទប់ទទួល ក្រោយពេលដែលពួកគាត់អង្គុយនៅក្នុងបន្ទប់ខារ៉ាអូខេ ពួកគាត់ទាំងបួននាក់ក៏បានចាប់ ចាប់មេក្រូដើម្បីច្រៀង។ ដោយយើងឃើញពួកម៉ាករបស់គាត់ម្នាក់ដែលឈរនៅខាងមុខតុ គាត់មាន គាត់ដែល ដែលគាត់ពាក់អាវពណ៌ពងមាន់ដៃខ្លី ដែលមានកាន់តេឡេនៅក្នុងដៃ កាន់តេឡេបញ្ជាទូរទស្សន៍នៅក្នុងដៃខាងឆ្វេង ដៃខាងស្តាំរបស់គាត់គឺគាត់កាន់ក្បាលមេក្រូ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងតេឡេបញ្ជានោះ មានន័យថានៅពេលដែលគាត់ចង់ច្រៀងបទអី
គាត់អាចចុចលេខចូលទៅក្នុងទូរទស្សន៍នោះ ដើម្បីឲ្យបទចម្រៀងនោះចេញមក
គាត់អាចច្រៀងបាន។ អញ្ចឹងពួកម៉ាករបស់គាត់ជាអ្នកបញ្ជា
ដោយគាត់កាន់តេឡេនៅក្នុងដៃរបស់គាត់ និងដៃម្ខាងទៀតកាន់ក្បាលមេក្រូ
ពួកម៉ាកគាត់ពីរអ្នកទៀតគឺអង្គុយនៅលើសាឡុង
អញ្ចឹងពួកគាត់អង្គុយមើលពួកម៉ាករបស់គាត់ច្រៀង។ អញ្ចឹងនិង
និងស្ត្រីដែលគាត់មានថ្ងៃខួបកំណើតនៅទីនេះ នៅថ្ងៃនេះ គាត់ក៏អង្គុយ គាត់អង្គុយម្នាក់ឯង
នៅលើសាឡុងមួយទៀត ដៃរបស់គាត់កាន់មេក្រូ និងនៅលើភ្លៅរបស់គាត់គឺមានសៀវភៅ
ដែលសៀវភៅនោះគឺសៀវភៅ គឺសៀវភៅចំណងជើងបទចម្រៀង ដែលគាត់អាច គាត់អាច
នៅពេលដែលគាត់ នៅពេលដែលគាត់ចង់ច្រៀងបទចម្រៀងមួយណា
គាត់អាចចុចលេខកូដនៅក្នុងសៀវភៅនោះចូល ដោយប្រើតេឡេទូរទស្សន៍ ចូលទៅក្នុងទូរទស្សន៍
ដូច្នេះគាត់អាចច្រៀងបទនោះបានយ៉ាងងាយស្រួល។ អញ្ចឹងការច្រៀងខារ៉ាអូខេគឺសប្បាយរីករាយ
ជាពិសេសគឺការច្រៀងជាមួយនឹងពួកម៉ាកជាច្រើន ការច្រៀងផង រាំផង អញ្ចឹងការច្រៀងផងរាំផង
នៅបន្ទប់ខារ៉ាអូខេជាមួយនឹងពួកម៉ាកច្រើន
អញ្ចឹងធ្វើឲ្យបរិយាកាសនៅទីនោះសប្បាយរីករាយណាស់។
អញ្ចឹងយើងឃើញនៅលើតុពួកគាត់មានភេសជ្ជៈ មានអាហារសម្រន់ អញ្ចឹង
អញ្ចឹងពួកគាត់ញ៉ាំបណ្ដើរ ពួកគាត់ច្រៀងលេងបណ្ដើរ ពួកគាត់ញ៉ាំបណ្ដើរ
ពួកគាត់ច្រៀងលេងបណ្ដើរ។

បន្ទាប់មកទៀតរូបភាពទី ៧ រូបភាពទី ៧ យើងឃើញគាត់បានបើកសៀវភៅចំណងជើងបទចម្រៀង
ដែល ដែលសៀវភៅចំណងជើងបទចម្រៀងនោះមានដាក់នូវលេខសម្គាល់
ដែលយើងហៅថាលេខកូដ ដែលយើងហៅថាលេខកូដ។
អញ្ចឹងនៅពេលដែលយើងពេញចិត្តនូវបទចម្រៀងមួយណា
យើងគ្រាន់តែវាយលេខកូដនោះចូលទៅក្នុង វាយលេខកូដនោះដោយប្រើតេឡេបញ្ជាទូរទស្សន៍
ចូលទៅក្នុងទូរទស្សន៍ ដូច្នេះយើងអាចច្រៀងបទណា
ដែលយើងចង់ច្រៀងនោះបានយ៉ាងងាយស្រួល។ អញ្ចឹងមានបទ
មានបទចម្រៀងជាច្រើននៅក្នុងសៀវភៅនោះ មានទាំងបទចម្រៀងជាភាសាខ្មែរ និងមាន
បទចម្រៀងជាភាសាអង់គ្លេស និងពេលខ្លះ សៀវភៅខ្លះក៏មានបទចម្រៀងជាភាសាចិនផងដែរ។

បន្ទាប់មកទៀតរូបភាពទី ៨ រូបភាពទី ៨ ក្រោយពេលដែលពួកគាត់ ពួកគាត់ប្រើ
ពួកគាត់ចុចបទចម្រៀងចូលក្នុងទូរទស្សន៍ អញ្ចឹងបទចម្រៀងនោះក៏បានចេញមក

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ក៏បានចេញមកពួកគាត់ក៏បានច្រៀង ពួកគាត់ក៏បានច្រៀងយ៉ាងសប្បាយរីករាយ។
អញ្ចឹងយើងឃើញពួកម៉ាករបស់គាត់ដែលឈរនៅខាងមុខតុនោះ ដែលមានកាន់តែឡេនៅក្នុងដៃ
គាត់ក៏បានដាក់តែឡេចុះ បន្ទាប់មកគាត់ក៏កាន់ក្បាលមេក្រូចាប់ផ្តើមច្រៀងលេង
និងពួកម៉ាកគាត់ពីរនាក់ទៀត ដែលអង្គុយនៅសាឡុងម្ខាងទៀត យើងឃើញ
យើងឃើញពួកម៉ាកគាត់ដែល យើងឃើញស្ត្រីដែលអង្គុយនៅ
យើងឃើញស្ត្រីដែលគាត់ពាក់អាវពណ៌ប្រផេះជាមួយនឹងសំពត់ពណ៌ស គាត់កាន់ទឹកក្រូច
ឬក៏បៀរនៅក្នុងដៃរបស់គាត់ គាត់មិនបានច្រៀងទេ គាត់មិនបានច្រៀងទេ
ដោយសារតែអត់មានក្បាលមេក្រូទំនេរ ដូច្នេះគាត់គ្រាន់តែអង្គុយមើលពួកម៉ាករបស់គាត់ច្រៀង។
និងស្ត្រីម្នាក់ទៀតដែលពាក់អាវយឺតពណ៌សជាមួយនឹងសំពត់ពណ៌ខៀវត្រឹមជង្គង់
គាត់កាន់ក្បាលមេក្រូច្រៀង អញ្ចឹងមានន័យថា គាត់បានយកក្បាលមេក្រូពី
ពីពួកម៉ាករបស់គាត់ដើម្បីយកមកច្រៀង។
ដោយសារតែប្រហែលជាពួកម៉ាករបស់គាត់ច្រៀងច្រើនបទហើយ និងមានអារម្មណ៍ថាឈឺក
ឬក៏មានអារម្មណ៍ថាចង់ឈប់ច្រៀងបន្តិច
អញ្ចឹងគាត់ក៏បានហុចក្បាលមេក្រូនោះឲ្យទៅពួកម៉ាករបស់គាត់ច្រៀងបន្ត។ អញ្ចឹងគាត់ក៏បានយក
គាត់ក៏បានលើកតែក្រូចឆ្មារយកមកញ៉ាំ ដើម្បីជួយសម្រួលបំពង់ករបស់គាត់ឲ្យជ្រះថ្លា ឲ្យជ្រះថ្លា
មានន័យថា មានន័យថាកុំឲ្យមានស្លេះ ឬក៏កុំឲ្យស្អកក
អញ្ចឹងគាត់អាចបន្តច្រៀងខារ៉ាអូខេទៀតក្រោយពេលដែលគាត់ញ៉ាំតែក្រូចឆ្មារនោះអស់។
អញ្ចឹងយើងឃើញពួកម៉ាករបស់គាត់ច្រៀងលេងយ៉ាងសប្បាយរីករាយ។

បន្ទាប់មកទៀតរូបភាពទី ៩ រូបភាពទី ៩ ពួកម៉ាករបស់គាត់បានទិញនំខេក បានទិញនំខេក
ឬក៏យើងអាចហៅបានថានំខួបកំណើត ដោយពួកគាត់ទិញបានផ្ញើទុកទៅ
បានផ្ញើទុកនៅបុគ្គលិករបស់ បុគ្គលិកនៅកន្លែងខារ៉ាអូខេនោះ ដើម្បីឲ្យពួកគាត់លើកមក
ដើម្បីធ្វើឲ្យពួកម៉ាករបស់គាត់ភ្ញាក់ផ្អើល។ អញ្ចឹងពួកគាត់មិនបានលើកនំនោះដោយផ្ទាល់ទេ
ពួកគាត់បានប្រាប់ឲ្យបុគ្គលិកនៅទីនោះបានលើកនំនោះ
មកដើម្បីធ្វើឲ្យពួកម៉ាករបស់គាត់ភ្ញាក់ផ្អើល។ អញ្ចឹងយើងឃើញបុគ្គលិកដែល
យើងឃើញមានបុរសម្នាក់ គាត់ពាក់ឯកសណ្ឋានជាបុគ្គលិកនៅ នៅខារ៉ាអូខេនោះ គាត់កាន់នំខេក
ឬក៏នំថ្ងៃខួបកំណើតនៅក្នុងដៃរបស់គាត់ទាំងពីរ ដោយយើងឃើញមានដាក់អក្សរ អាយុម្ភៃបីឆ្នាំ
អញ្ចឹងមានន័យថាស្ត្រីម្នាក់នោះគាត់មានអាយុ ២៣ ឆ្នាំ។
ដូច្នេះថ្ងៃនេះគឺជាថ្ងៃខួបកំណើតគម្រប់អាយុម្ភៃបីឆ្នាំរបស់គាត់។
អញ្ចឹងពួកម៉ាករបស់គាត់បានទិញនំខួបកំណើតដើម្បីធ្វើឲ្យគាត់ភ្ញាក់ផ្អើល។
អញ្ចឹងនៅពេលដែលបុរសនោះចូលមកខាងក្នុង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ពួកគាត់ក៏បានច្រៀងចម្រៀងខួបកំណើតទៅឲ្យពួកម៉ាករបស់គាត់ ទៅឲ្យពួកម៉ាករបស់គាត់
អញ្ចឹងពួកម៉ាករបស់គាត់ នៅពេលដែលឃើញនំខួបកំណើតនោះ គាត់មាន គាត់
ទឹកមុខរបស់គាត់សប្បាយចិត្ត និងភ្ញាក់ផ្អើលយ៉ាងខ្លាំង
ដោយសារតែគាត់មិនដឹងថាពួកម៉ាករបស់គាត់បាន
ដោយសារតែគាត់មិនដឹងថាពួកម៉ាករបស់គាត់បានទិញនំនោះឲ្យគាត់ទេ។
អញ្ចឹងគាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង និងជាមួយនឹងទឹកមុខសប្បាយរីករាយ
ជាមួយនឹងទឹកមុខសប្បាយរីករាយ។

បន្ទាប់មកទៀត បន្ទាប់មកទៀតរូបភាពទី ១០ រូបភាពទី ១០
ក្រោយពេលដែលបុរសម្នាក់នោះបានយកនំខេកចូលមកខាងក្នុង
យើងឃើញពួកម៉ាករបស់គាត់ដែលពាក់អាវដៃខ្លីពណ៌ប្រផេះ ជាមួយនឹងសំពត់ពណ៌ស ត្រឹមជង្គង់
ក៏បានយកនំខេកនោះមកកាន់ លើកឡើងលើបន្តិច ដើម្បីឲ្យស្ត្រីម្នាក់នោះគាត់ផ្លុំ គាត់ផ្លុំទៀន
អញ្ចឹងដើម្បីឲ្យគាត់ផ្លុំទៀន និងធ្វើការបួងសួង នៅថ្ងៃខួបកំណើតរបស់គាត់គម្រប់អាយុ ២៣
ឆ្នាំនោះ។ អញ្ចឹងយើងឃើញនំខួបកំណើតនោះ មិនធំ មិនតូច គឺល្មម គឺល្មម ដែលមានដាក់លេខ
២៣ នៅលើនំនោះ អញ្ចឹងគាត់ក៏បានយកនំនោះលើកឡើងលើបន្តិច
និងឲ្យស្ត្រីម្នាក់នោះធ្វើការផ្លុំទៀន អញ្ចឹងពួកម៉ាកគាត់ពីរនាក់ទៀត ទះដៃអបអរសាទរ
ដោយទឹកមុខសប្បាយរីករាយ និងញញឹម ដោយទឹកមុខញញឹម និងសប្បាយរីករាយ។

បន្ទាប់មកទៀតរូបភាពទី ១១ រូបភាពទី ១១ ក្រោយពេលដែលគាត់បានផ្លុំទៀន ផ្លុំទៀនហើយ
គាត់ក៏បានកាត់នំនោះឲ្យទៅពួកម៉ាករបស់គាត់ញ៉ាំ គាត់ក៏បានកាត់នំ
គាត់ក៏បានកាត់នំខួបកំណើតនោះឲ្យទៅពួកម៉ាករបស់គាត់ញ៉ាំ
បន្ទាប់មកស្ត្រីម្នាក់នោះគាត់ក៏បានក្រោកឈរ ដើរទៅឈរនៅខាងមុខតុ នៅខាងមុខទូរទស្សន៍
និងគាត់ក៏បានច្រៀងបន្តទៀត ដោយទឹកមុខសប្បាយរីករាយ ដោយការ
ដោយទឹកមុខសប្បាយរីករាយយ៉ាងខ្លាំង។ អញ្ចឹងយើងឃើញពួកម៉ាករបស់គាត់ពីរអ្នកទៀត
ដែលអង្គុយនៅលើ ដែលអង្គុយនៅលើសាឡុងនោះ ពួកគាត់ញ៉ាំនំខេក អញ្ចឹងដៃទាំង
ដៃរបស់គាត់មានកាន់នំខេកនៅក្នុងដៃ ដៃម្ខាងទៀតគឺកាន់ស្លាបព្រា អញ្ចឹងគាត់កាន់
អញ្ចឹងពួកគាត់ទាំងពីរញ៉ាំនំខេកដែលស្ត្រីម្នាក់នោះបានកាត់ បានកាត់ដាក់ចានឲ្យ
និងយើងឃើញពួកម៉ាករបស់គាត់ម្នាក់ទៀតអង្គុយនៅកន្លែងគាត់ ដោយយើងឃើញគាត់មានកាន់
គាត់កាន់ស្រាបៀរ ឬក៏ជាកូកាកូឡា ដើម្បីញ៉ាំ ដើម្បីញ៉ាំឲ្យបាត់ ឲ្យបាត់ស្រេកទឹក
ប្រហែលជាដោយសារតែគាត់ច្រៀង ច្រៀងហត់ពេក ឬក៏ប្រហែលជាគាត់ច្រៀង ច្រៀងស្ងួតកពេក

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដូច្នេះគាត់ក៏បានញ៉ាំកូកា គាត់ក៏បានអង្គុយនិងញ៉ាំកូកាសិន។ និងគាត់អង្គុយមើលញ៉ាំបណ្ដើរ
មើលពួកម៉ាករបស់គាត់ច្រៀងលេងបណ្ដើរ។

បន្ទាប់មកទៀតរូបភាពទី ១២ រូបភាពទី ១២ នៅពេលដែលពួកគាត់ច្រៀងចប់
នៅពេលដែលពួកគាត់ច្រៀងចប់ និងដល់ម៉ោងត្រូវត្រលប់ទៅផ្ទះវិញ ពួកគាត់ក៏បានចុចប៊ូតុង
ដើម្បីឲ្យហៅបុគ្គលិកនៅទីនោះមកគិតលុយ
អញ្ចឹងខារ៉ាអូខេខ្លះគឺមានប៊ូតុងប្រើសម្រាប់ចុចប្រាប់ជាដំណឹងទៅឲ្យបុគ្គលិកចូលមកគិតលុយ
កន្លែងខ្លះយើងត្រូវចេញទៅខាងក្រៅប្រាប់បុគ្គលិកដោយផ្ទាល់។ អញ្ចឹងដោយសារតែផ្សារទំនើបនេះ
បន្ទប់ខារ៉ាអូខេគឺស្អាតនិងទំនើប ដូច្នេះ និងទំនើប និងមានភាពងាយស្រួលផង ដូច្នេះពួកគាត់បាន
បានដាក់ប៊ូតុងមួយសម្រាប់ឲ្យភ្ញៀវចុច នៅពេលដែលចង់ហៅពួកគាត់ចូល
នៅពេលដែលចង់ហៅពួកគាត់ចូលមកខាងក្នុង ឬក៏នៅពេលដែលចង់ហៅ ចង់កុម្ម៉ង់អ្វីមួយ
អាចចុចប៊ូតុងនេះ ពួកគាត់នឹងចូលមកខាងក្នុងបាន។ យើងឃើញនៅក្បែរប៊ូតុងនោះ
យើងឃើញកែវ កែវដែលមានក្រូចឆ្មារ ក្រូចឆ្មារ អញ្ចឹងគាត់បានញ៉ាំទឹកក្រូចឆ្មារនោះ
ដើម្បីធ្វើឲ្យបំពង់ករបស់គាត់ស្រស់ថ្លា និងមិនមានការស្អកក និងមិនមានការស្អកក។

បន្ទាប់មកទៀតរូបភាពទី ១៣ រូបភាពទី ១៣ ពួកគាត់ទាំងបួននាក់ក៏បាន ពួកគាត់
ពួកគាត់ទាំងបួននាក់ នៅពេលដែលឃើញបុគ្គលិកចូលមកខាងក្នុង ពួកគាត់ក៏ប្រាប់ឲ្យគិតលុយ
អញ្ចឹងបុគ្គលិកនោះក៏បានប្រមូលភេសជ្ជៈ ដែលនៅសល់ ភេសជ្ជៈដែលនៅសល់
ដែលពួកគាត់ទាំងបួននាក់មិនបានញ៉ាំ ដើម្បីយកទៅខាងក្រៅដើម្បីងាយស្រួលគិតលុយ។
អញ្ចឹងភេសជ្ជៈដែលពួកគាត់ញ៉ាំ អញ្ចឹងយើងអាចរាប់ទៅតាមហ្នឹង យើងអាចរាប់ទៅតាមហ្នឹង។
អញ្ចឹងគាត់ញ៉ាំអស់ប៉ុន្មានយើងអាចកត់ត្រាទៅតាមហ្នឹង
យើងគ្រាន់ប្រមូលតែរបស់ណាដែលពួកគាត់នៅសល់ មានន័យថារបស់ដែលពួកគាត់អត់បានញ៉ាំ
ដើម្បីងាយស្រួលគិតលុយ ដើម្បីងាយស្រួលគិតលុយ។

បន្ទាប់មកទៀតរូបភាពទី ១៤ រូបភាពទី ១៤ ក្រោយពេលគិតលុយរួចរាល់ហើយ
យើងឃើញពួកគាត់មិនបានញ៉ាំនំខេកអស់ទេ យើងឃើញនំខេក ឬក៏នំខួបកំណើត
គឺនៅសល់មួយចំណិតទៀតនៅលើតុ។ ប៉ុន្តែពួកគាត់ក៏មិនបានយកទៅផ្ទះវិញដែរ
ដោយសារតែពួកគាត់ញ៉ាំឆ្អែត និងសប្បាយរីករាយជាមួយនឹងការច្រៀង
ជាមួយនឹងការច្រៀងខារ៉ាអូខេជាមួយគ្នា។ បន្ទាប់មកពួកគាត់ក៏បានដាក់មេក្រូនៅលើ
ដាក់មេក្រូទាំងពីរនៅលើសាឡុង បន្ទាប់មកពួកគាត់ក៏បានដើរចេញ ដើរចេញទៅខាងក្រៅដើម្បី
ដើម្បីត្រលប់ទៅផ្ទះវិញ ដើម្បីត្រលប់ទៅផ្ទះវិញ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងយើងឃើញស្ត្រីដែលគាត់មានថ្ងៃខួបកំណើតនៅថ្ងៃនេះ
គាត់បានដើរនាំមុខពួកម៉ាករបស់គាត់ទាំងបីនាក់។

បន្ទាប់មកទៀតរូបភាពទី ១៥ [រូបភាព] រូបភាពទី ១៥
ពួកគាត់ក៏បានដើរចុះមកខាងក្រោមតាមជណ្ដើរយន្ត ដើរចេញមកខាងក្រៅ
ដោយសារតែផ្ទះរបស់ពួកគាត់ទាំងបួននាក់ នៅផ្លូវខុសៗគ្នា ដូច្នេះពួកគាត់ក៏បានលាគ្នា
ដើម្បីដើរត្រលប់ទៅផ្ទះវិញរៀងៗខ្លួន។
អញ្ចឹងថ្ងៃខួបកំណើតរបស់គាត់គឺជាថ្ងៃមួយដែលសប្បាយរីករាយ
ដោយសារតែមានការចូលរួមពីពួកម៉ាករបស់គាត់ ជាពួកម៉ាកជិតស្និទ្ធរបស់គាត់ និងមានការ និងមាន
និងមានការធ្វើឲ្យភ្ញាក់ផ្អើល និងមានការភ្ញាក់ផ្អើល ដោយសារតែពួកម៉ាករបស់គាត់
បានទិញនំខួបកំណើត និងបានឲ្យអ្នក និងបានឲ្យបុគ្គលិកនៅ
និងបានឲ្យបុគ្គលិកនៅក្នុងហាងខារ៉ាអូខេនេះយកមកឲ្យ
អញ្ចឹងបានធ្វើឲ្យគាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។
អញ្ចឹងថ្ងៃនេះពួកគាត់បានញ៉ាំនំខេកដែលមានរសជាតិឆ្ងាញ់
ជាមួយនឹងការច្រៀងខារ៉ាអូខេយ៉ាងសប្បាយរីករាយ។ ដូច្នេះនៅពេលដែលពួកគាត់លាគ្នា
អញ្ចឹងយើងឃើញពួកគាត់លើកដៃ លើកដៃស្ដាំឡើងលើម្នាក់ៗដើម្បីលាគ្នាត្រលប់ទៅផ្ទះវិញ
ដោយទឹកមុខសប្បាយរីករាយ និងចងចាំថ្ងៃនេះ និងចងចាំថ្ងៃសប្បាយនេះជានិច្ច។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.